## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ**

**លេខ**.....៣៣.ស.សរ......

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការ ត្រួតពិនិត្យវាយតម្លៃលើគម្រោង ជួសជុលព្រះសក្យមុនីចេតិយ នៅភ្នំព្រះរាជទ្រព្យ ស្រុកពញាឮ ខេត្តកណ្តាល

### រដ្ឋមន្ត្រី ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានឃើញអនុក្រឹត្យលេខ ២៤អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- យោងចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤ លើលិខិតលេខ ១១វ.ប.ក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

## សម្រេច

**ប្រការ១.-**

បង្កើតគណៈកម្មការ ទទួលបន្ទុកត្រួតពិនិត្យវាយតម្លៃលើគម្រោងជួសជុល ព្រះសក្យមុនីចេតិយ នៅភ្នំព្រះរាជទ្រព្យ ស្រុកពញាឮ ខេត្តកណ្តាល ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- ឯកឧត្តម **ជុច ភឿន** | | រដ្ឋលេខាធិការ | ប្រធាន |
| ២- ឯកឧត្តម **អ៊ិន ទឹម** | | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣- ឯកឧត្តម **ហ៊ី វ៉ៃ** | | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៤- ឯកឧត្តម **ហាប់ ទូច** | | អគ្គនាយកបេតិកភណ្ឌ | សមាជិក |
| ៥- លោក | **ប្រាក់ សុណ្ណារ៉ា** | អគ្គនាយករងបេតិកភណ្ឌ | សមាជិកអចិន្ត្រៃយ៍ |
| ៦- លោក | **យុន អាន** | អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ៧- ឯកឧត្តម | **ចំន្ទ វណ្ណា** | ប្រធាននាយកដ្ឋានសម្ភារៈបរិក្ខារ | សមាជិក |
| ៨- ឯកឧត្តម | **សុខ អឿន** | ប្រធានមន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តកណ្តាល | សមាជិក |
| ៩- លោក | **គឹម សុផិន** | ប្រធាននាយកដ្ឋានគាំពារនិងអភិរក្សសំណង់បុរាណ | សមាជិក |
| ១០- លោក | **ម៉ាន់ វ៉ៃ** | ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ | សមាជិក |
| ១១- លោក | **ង៉ែត សុវណ្ណារិទ្ធ** | ប្រធានការិយាល័យគណនេយ្យ | សមាជិក |

**ប្រការ២.-**

គណៈកម្មការមានភារកិច្ចៈ

- ពិនិត្យគម្រោងបញ្ជីប៉ាន់តម្លៃដែលបានលើកឡើងដោយក្រុមការងារជួសជុលព្រះសក្យមុនីចេតិយ
- រៀបចំឯកសារ និងដំណើរការចរចាថ្លៃឲ្យបានត្រឹមត្រូវស្របតាមនីតិវិធីហិរញ្ញវត្ថុ
- រៀបចំកិច្ចសន្យា ឬកិច្ចព្រមព្រៀងជាមួយភាគីទទួលជួសជុលព្រះសក្យមុនីចេតិយ
- ត្រួតពិនិត្យវាយតម្លៃលើការងារជួសជុលតាមដំណាក់កាលនីមួយៗ
- ត្រួតពិនិត្យលក្ខណៈបច្ចេកទេសនៃការជួសជុលឲ្យមានគុណភាពល្អប្រសើរបំផុត
- រៀបចំឯកសារទូទាត់ជូនអ្នកទទួលការក្រោយពីបានធ្វើការវាយការតម្លៃ និងមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- ធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំបានជ្រាបពីដំណាក់កាលនីមួយៗ រហូតបានបញ្ចប់ការងារជាស្ថាពរ
- សមាជិកគណៈកម្មការទាំងអស់ត្រូវចូលរួមតាមការកោះអញ្ជើញរបស់ប្រធាន។

**ប្រការ៣.-**

នាយកខុទ្ទកាល័យ អធិការ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកបេតិកភណ្ឌ នាយកដ្ឋានគាំពារនិងអភិរក្សសំណង់បុរាណ នាយកដ្ឋានបុរាណវត្ថុ គ្រប់អង្គភាពពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចប្រការ១ត្រូវ ទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែមីនា ឆ្នាំ ២០១៤

**រដ្ឋមន្ត្រី**

ភឿង-សកុណា

**ចម្លងជូន**

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-សាលាខេត្តកណ្តាល

« ដើម្បីជ្រាបជាព័ត៌មាន »

-នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ

-ដូចប្រការ៣ « ដើម្បីអនុវត្ត »

-ឯកសារ-កាលប្បវត្តិ